# បទបង្ហាញស្តីពី

# បច្ចុប្បន្នភាពនៃអំពើពពោះជំនួស និងការឆ្លើយតបរបស់រាជរដ្ឋាភិបាល ចំពោះការពពោះជំនួស

លោកស្រី រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរងនៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៧

## ហេតុការណ៍

- ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ មានការបង្ក្រាបករណីអំពើធ្វើអន្តរការីសម្រាប់ការពពោះ ដោយអនុលោមតាមមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ។
- ជនសង្ស័យជាជនជាតិអូស្រ្តាលី និងជនជាតិខ្មែរ២រូប កំពុងស្ថិតនៅក្រោមនៃសាលាដំបូងរាជធានីភ្នំពេញ ។
- តាមចម្លើយ មានស្រ្តី៥២ នាក់ បានមកពិនិត្យសុខភាពដើម្បីបញ្ចូលមេជីវិត នៅមន្ទីរពេទ្យកម្ពុជា និងមន្ទីរពេទ្យវឌ្ឍនៈ មានតែ១២នាក់ទេដែលជោគជ័យ
- ជនសង្ស័យ ធ្លាប់បានប្រកបរបរជួលស្ត្រីពពោះនេះនៅប្រទេសថៃ ឆ្នាំ២០១៣ បាន១៥នាក់ តែថៃបិទ ហើយបង្វែរមកកម្ពុជា .នៅពេលប្រទេសថៃប្រកាសបិទ
- កន្លងមកមានទារកចំនួន ៣៣ នាក់ ដែលទទួលបានសញ្ញាតិបរទេសពីស្ថានទូតរបស់សាម៉ីខ្លួនជនបរទេសជាអ្នកស្នើសុំ បានចុះបញ្ជីស្នើសុំទិដ្ឋាការនាំចេញទៅបរទេសរួចហើយ ដែលអាចអាចតាមអន្តរការីដទៃទៀត។
- ក្នុងនោះ ជាទារកកើតពីម្តាយជាជនជាតិខ្មែរចំនួន ២៨ នាក់ និងពីជនជាតិថៃ ចំនួន ៥ នាក់។
- មកទល់ពេលនេះមានប្រមាណ៥០ទារកទៀត ដែលកើតរួច រងចាំការអនុញ្ញាតនាំចេញ

## ច្បាប់ពាក់ព័ន្ធ

ព្រះរាជអាជ្ញាបានចោទប្រកាន់តាមច្បាប់:

- ក្រមព្រហ្មទណ្ឌ: មាត្រា៣៣២ (អន្តរការរវាងអ្នកសុំកូន និងស្ត្រីពរពោះ) ដាក់ពន្ធនាគារពី ១ខែ ទៅ ៦ខែ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ ១លានរៀល និងមាត្រា៦៣២ (សុំឲ្យផ្តល់ឯកសារដោយទុច្ចរិត)
- ដោយការនាំចេញដែលធ្វើឡើងដោយអន្តរការីពុំមានអាណាព្យាបាលពិតប្រាកដ មកបំពេញបែបបទតាមផ្លូវច្បាប់ គឺអាចជាការរត់ពន្ធឬជួញដូរទារក
- ប្រកាសក្រសួងសុខាភិបាល លេខ៦៧៩ ប្រក/សនក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងឈាម មេជីវិត ខួរឆ្អឹង និងកោសិកាដើមរបស់មនុស្ស (ប្រការ១២: រាល់ការពពោះជំនួស ដែលជាសេវាមួយនៃកញ្ចប់សេវានានានៃការជួយឲ្យមានកូនតាមបែបបទបច្ចេកទេសវិទ្យាសាស្ត្រ ត្រូវហាមឃាត់ដាច់ខាត។)
- កម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញា កតិកាសញ្ញាអន្តរជាតិពាក់ព័ន្ធសិទ្ធកុមារ សិទ្ធិមនុស្ស និងការប្រឆាំងឧក្រិដ្ឋកម្មនានា ជាពិសេស អំពើជួញដូរមនុស្ស ដែលមិនអាចមើលរំលងករណីនេះបានឡើយ
- ករណីនេះជាសញ្ញាណនៃការជួញដូរមនុស្ស (តម្លៃតាំងពីនៅក្នុងពោះ បើកូនល្អបានអោយថ្លៃពេញ បើកូនមិនពេញលក្ខណៈ អ្នកចង់បានកូនមិនយកឬទំលាក់ថ្លៃ...)

## ផលប៉ះពាល់

- ស្ត្រីកាន់តែច្រើន អាចយកការពពោះជំនួសជាមុខរបរ ដោយផ្អែកលើភាពក្រីក្រ
- បញ្ហាសុខភាព - ការពពោះមានការប្រឈមនឹងបញ្ហាសុខភាពរបស់ម្តាយ តាំងពីពេលពពោះ ពេលសម្រាលកូន (ភាគច្រើនដោយការវះកាត់) និងប៉ះពាល់ផ្លូវចិត្ត ពេលគេបំបែកយកកូនទៅប្រទេសគោលដៅ។
- សីលធម៌ និងគុណធម៌របស់មនុស្សធ្លាក់ចុះ - បញ្ហាទំនៀមទម្លាប់ប្រពៃណីរបស់ស្ត្រី គ្រួសារ និងសង្គមខ្មែរ ត្រូវបានបំផ្លាញ
- បានរកឃើញស្ត្រីនៅលីវបានយល់ព្រមពពោះ, តម្លៃមនុស្សនៅលើលុយ មិនមែនសេចក្តីថ្លៃថ្នូរ ...
- កម្ពុជានិងអាចក្លាយទៅជាគោលដៅផលិតទារកដើម្បីនាំចេញទៅលក់នៅប្រទេសក្រៅ ???
- ខុសមាត្រាច្បាប់កម្ពុជា ដែល ក្នុងករណីស្ត្រីពពោះមាននិតិសង្វាស មិនបានអនុវត្តមាត្រា៩៨៩ និងមាត្រា៩៩០ នៃក្រមរដ្ឋប្បវេណី (ស្វាមីរបស់ស្ត្រីអាចប្តឹងជំទាស់តវ៉ា) និងច្បាប់ឯកពន្ធភាព

## ជាដំណោះស្រាយ

- បានជួបពិភាក្សា ជាមួយស្ថានទូតអូស្ត្រាលី បីលើក
- បានរៀបចំកិច្ចប្រជុំអន្តរក្រសួង និងដៃគូពាក់ព័ន្ធចំនួន៥លើក និងជំនួបរបស់សម្តេចក្រឡាហោម លោកជំទាវដូប៉ុន អេង ជាមួយស្ថានទូតអូស្ត្រាលី ក្នុងការរកដំណោះស្រាយឆ្លើយតបទៅនឹងករណីដែលកំពុងកើតឡើង
- ស្នើឲ្យភាគីអូស្ត្រាលី សហការជាមួយរដ្ឋាភិបាលកម្ពុជា លើបីចំនុចៈ

១- សុំអោយផ្អាកការស្នើសុំពពោះជំនួស ដើម្បីបង្ការកុំឲ្យមានករណីថ្មីកើតឡើង

២- ដោះស្រាយករណីដែលកំពុងមាន ដោយមានការសហការពីអ្នកចង់បានកូន ដោយទទួលខុសត្រូវជានាដល់សុវត្ថិភាពស្ត្រីពពោះ តាមដែលបានសន្យារួច

៣- រៀបចំនិតិវិធីរួមគ្នា ឲ្យបានសមស្រប ត្រឹមត្រូវ ដើម្បីដោះស្រាយករណីដែលកើតមានរួច។ ចំពោះករណីថ្មី ត្រូវរង់ចាំការណែនាំថ្មីពីរាជរដ្ឋាភិបាល និងច្បាប់កំណត់ ។

- កិច្ចប្រជុំទី៥ បានឯកភាពលើមតិរបស់ ឯកឧត្តម កើត រិទ្ធ តំណាងក្រសួងយុត្តិធម៌ លើវិធានការជាជម្រើសពីរ គឺៈ
- (១) ផ្តល់ដំណោះស្រាយតាមច្បាប់ស៊ីវិល ករណីដែលកំពុងកើតមាន
- (២) ការពង្រឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌ ។
- ដែលជម្រើសនីមួយៗ គឺជាការគិតគូដល់ឧត្តមប្រយោជន៍របស់ទារកផង ជាការអនុវត្តតាមច្បាប់កម្ពុជាផង និងជាការផ្តល់សិទ្ធិដល់ស្ត្រីជាម្តាយ អ្នកពពោះផង ។

## ជាដំណោះស្រាយ (ត)

- វិធានការទាំងពីរនេះ មានផលប៉ះពាល់ខុសគ្នា គឺៈ

**ផលប៉ះពាល់ទី១៖** នឹងមានអ្នកចេញមុខមកស្នើសុំទារកជាច្រើនទៀត ដោយពុំមានបារម្ភអំពី ផ្លូវច្បាប់ និងទោសទណ្ឌ ។ ក្នុងន័យនេះ រដ្ឋាភិបាល ត្រូវមានវិធានការហាមប្រាមចំពោះ ករណីថ្មី ដែលមិនគួរឲ្យកើតមានបន្តទៀតឡើយ ហើយចាំបាច់ ត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌ ។

**ផលប៉ះពាល់ទី២៖** ករណីពពោះ នឹងស្ងប់ស្ងាត់ តែទារកដែលបាន និងកំពុងតែនៅក្នុងពោះម្តាយ និងកើតហើយ នឹងប្រឈមជាមួយហានិភ័យក្នុងការទទួលខុសត្រូវចិញ្ចឹមបីបាច់ ការធានាផ្នែកច្បាប់ និងសម្ពាធផ្នែកអារម្មណ៍ (trauma) រហូតពេញវ័យ ឬមួយជីវិត ។

- និង កិច្ចប្រជុំអន្តរក្រសួងមួយកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រោមអធិបតីភាពសម្តេចក្រឡាហោម កំណត់សម្រេច ស្នើសុំគោលការសម្តេចនាយក ផ្អែកលើគោលការណ៍ចម្បងពីរ គឺៈ

(ទី១) ជានាបាននូវការអនុវត្តតួនាទីរបស់អាជ្ញាធររដ្ឋក្នុងការការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋខ្លួន ជាពិសេស លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីកុំឱ្យកម្ពុជាក្លាយជាគោលដៅនៃ ការធ្វើអាជីវកម្មពពោះជំនួស និង

(ទី២) ជានាផលប្រយោជន៍របស់ទារក ដែលកកំណើត ឬដែលបានកើតមកហើយ។